# សេចក្តីថ្លែងការណ៍រួម

## សង្គមស៊ីវិលសំដែងការព្រួយបារម្ភចំពោះស្ថានភាពវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា

សម្ព័ន្ធ នៃ អង្គការមិនមែនរដ្ឋាភិបាល រួមមាន គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិកម្ពុជា（CHRAC）វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា（NGO Forum）និងក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន（HRTF）សូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះវិវាទដីធ្លី ដែលបានកើតឡើងនាពេលកន្លងមក ដែលភាគច្រើនវិវាទដីធ្លីទាំងនោះមិនទាន់បានដោះស្រាយទៅតាមយន្តការនៃការដោះស្រាយវិវាទដីធ្លី និងច្បាប់ជាធរមាននៅឡើយ ។

នាពេលថ្មីៗនេះ វិវាទដីធ្លីនៅតែបន្តកើនឡើងតាមរយៈការអភិវឌ្ឍន៏របស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះវិវាទភាគច្រើនកើតឡើងពាក់ព័ន្ធរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុន រួមមានទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេសផងដែរ ក៏ដូចជាពាក់ព័ន្ធរវាងប្រជាពលរដ្ឋ និងអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច ។ ជាពិសេសទៅទៀតនោះករណីវិវាទដែលកើតមានឡើងដែលប៉ះពាល់ដល់ប្រជាពលរដ្ឋច្រើនគ្រួសារនោះគឺ ភាគច្រើនវិវាទជាមួយក្រុមហ៊ុន ទទួលសម្បទានដីសេដ្ឋកិច្ច ។ ជាការកត់សំគាល់នាពេលកន្លងមក ស្ថានភាពទូទៅនៃវិវាទដីធ្លីកើតឡើង និងបញ្ចប់ទៅវិញដោយការប្រើអំពើហិង្សា ឬមិនទាន់បានដោះស្រាយនៅឡើយ ខណៈពេលដែលមានករណីមួយចំនួនតូចប៉ុណ្ណោះ ដែលបានដំណើរការដោះស្រាយតាមផ្លូវច្បាប់ ។

យោងតាមការវិភាគទន្និន័យ ស្តីពី ករណីវិវាទដីធ្លីរបស់សង្គមស៊ីវិល ក្នុងឆ្នាំ២០០៨, ២០០៩ និងដើមឆ្នាំ ២០១០ យើងឃើញថាមានការកើនឡើងជាលំដាប់ តួរលេខករណីដូចជា ៣៦.៥% ក្នុងឆ្នាំ២០០៩ បើធៀបនិងឆ្នាំ ២០០៨ ហើយ ៣៤.៣% ក្នុងដើមឆ្នាំ២០១០ បើធៀបនិងឆ្នាំ២០០៩ ។ ស្ថានភាពនៃការដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០០៩ កន្លងមក ក្នុងចំណោម ២៣៦ ករណី ដែលប្រមូលបានមានតែ ១៧.៤% ប៉ុណ្ណោះ ដែលបានឆ្លងកាត់ដំណើរការដោះស្រាយ ចំណែកឯ ៦៧.៤% ផ្សេងទៀត មិនទាន់មានការដោះស្រាយនៅឡើយទេ ។

ក្នុងនាមជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិល សូមស្វាគមន៏ចំពោះការយកចិត្តទុកដាក់ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញក្រុមហ៊ុនវិនិយោគនានា ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៏ប្រទេសជាតិ តាមរយៈការធ្វើសម្បទានដីសេដ្ឋកិច្ច ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ យើងក៏មានការសោកស្តាយ និងបដិសេធដាច់ខាត ចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចណាដែលផ្ទុយនឹងច្បាប់ មិនអនុវត្តន៏តាមអនុក្រឹត្យ និងរំលោភសិទ្ធិមនុស្ស ដោយធ្វើឱ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ

ជាច្រើនគ្រួសារ ដែលមិនបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។

*ដូចនេះ សម្ព័ន្ធ នៃអង្គការសង្គមស៊ីវិល សូមផ្តល់ជូននូវអនុសាសន៍មួយចំនួន ដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាធ្វើការពិចារណា ដូចខាងក្រោមនេះ ៖*

១-សូមធ្វើការអភិវឌ្ឍន៍ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីជៀសវាងផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រ

២-សូមធ្វើការដោះស្រាយវិវាទដីធ្លីដោយទទួលបាននូវសំណងសមរម្យ និងមានការយល់ព្រមពីភាគីទាំងពីរ

៣-ស្នើពង្រឹងយន្តការដោះស្រាយវិវាទដីធ្លីឱ្យកាន់តែមានប្រសិទ្ធិភាពឡើង

៤-សូមបញ្ឈប់ការចាប់ខ្លួនប្រជាពលរដ្ឋដោយករណីវិវាទដីធ្លី

៥-សូមឱ្យអាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដីធ្លីចូលរួមដោះស្រាយឱ្យបានសកម្មតាមជំនាញរបស់ខ្លួន ជៀសវាងការប្រើយន្តការដោះស្រាយក្រៅនិតិវិធីច្បាប់ ។

៦-សូមអោយកងកំលាំងប្រដាប់អាវុធការពារផលប្រយោជន៍ប្រជាពលរដ្ឋ កុំអោយការពារតែឈ្មួញ ។

ភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល គណៈកម្មាធិការប្រព្រឹត្តិកម្ម (CHRAC) និងជា នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ (KID) | ទូរស័ព្ទលេខ៖ ០១២ ៨៦៥ ៩១០ |
| លោក **ចាន់ សុវ៉េត** | ប្រធានផ្នែកស៊ើបអង្កេតសិទ្ធិមនុស្សនៃសមាគមអាដហុក (ADHOC) | ទូរស័ព្ទលេខ៖ ០១៦ ៩៣៧ ៥៩១ |
| លោក **ឈិត សំអាត** | នាយកប្រតិបត្តិ NGO Forum | ទូរស័ព្ទលេខ៖ ០១២ ៩២៨ ៥៨៥ |
| លោក **សៀ ភារម្យ** | នាយកលេខាធិការដ្ឋាន ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF) | ទូរស័ព្ទលេខ៖ ០១២ ៨៥២ ៣២៥ |